Khmer Story Lovers

# [illegible]

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិ ផ្ទះលេខ ២៨ ផ្លូវលេខ ២៤៥ ដីឡូត៍លេខ ២៥៨ បឹងកេងកង សង្កាត់លេខ ៩ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ចិនតុងសើចយកៗ :

-ឲ្យតែទៅដល់ផ្ទះលោកយានគួង នៅស្រុកយាស៊ីន បានជួបគាត់ហើយ ! ឪពុកម្ដាយបងជាមនុស្សចាស់ ទូលកប៉ុណ្ណឹងដែរ, បងខ្លាចគាត់ធ្វើផ្លូវឬ ?

- ខ្ញុំដឹងហើយ, ពុកគិនម៉ែធ្លាប់ដើរផ្សងព្រេងពេញពិភពលោក, មិនអាចធ្វើផ្លូវដូចក្មេងៗឡើយ ។

អ្នកទាំងពីរសំណេះសំណាលគ្នាលេងតាមផ្លូវវេញ្ញាក់ ស៊ុំផាងល្អណាស់ទាំងគំនិតប្រាជ្ញា ទាំងយុទ្ធសិល្បៈ ក្រោមការអប់រំរបស់អ្នកស្រីវុនយូ បណ្ដាលឲ្យចិនតុងសប្បាយរីករាយខ្លាំងឡើង និកថា :

-តាំងពីណើជួបម្ដងមក, បងបានក្មេងរៀនចាស់អស់ហើយ តែផ្លូវ, ទិយាយះអើទៅក៏គាត់បងចាំដែរ ណែងក្មេងទៀតហើយ ហាក់ដូចជាដឹងជាងកាលជួបយើងលើកមុនច្រើនណាស់ ។

នៅតាមផ្លូវនាងរៀបរាប់រឿងរ៉ាវក្នុងពិភពលោក ប្រាប់ហាក់ណាយ៉ាងក្បោះក្បាយ ។

នៅពេលថ្ងៃត្រង់អ្នកទាំងពីរទៅដល់ទីប្រជុំជនមួយ ។ ចិនតុងនាំស៊ុំផាងចូលតៀមហូបបាយ តែឥតមានតុទំនេរសោះ ។ អ្នកបំរើនាំយុវជនទាំងពីរទៅអង្គុយតុតូចមួយកៀនជញ្ជាំង ហើយ គេនាំគ្នាទៅបំរើភ្ញៀវយ៉ាងច្រើន ដែលអង្គុយចាំមុនទៅតុធំៗ បី

អ្នកប្រែសម្រួល : អ.គឹមសាន

តម្លៃ ៣៛០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៣០

ដោយលែងរវល់នឹងភ្ញៀវមកក្រោយទៀត ។

ចិនតុងពេលក្ដុកមើលភ្ញៀវមួយក្រុមនោះ ឃើញគ្នាដប់នាក់ប្លាយ, មានស្រីបីនាក់ អាយុពាក់កណ្ដាលមនុស្ស ។ អ្នកទាំងអស់កាន់អាវុធគ្រប់ដៃ និយាយគ្នាដូចអ្នកស្រុកនៅជិតខាងកើត ។ គេផឹកស្រាជែកគ្នាអឺកអឹង ខ្លាចរអាអ្នកណាឡើយ ។

ចិនតុងនឹកថា :

អ្នកគុននិយមមួយក្រុមនេះ ប្រហែលជាសមាជិកក្រុមហ៊ុនដឹកនាំណាមួយនៅជាយដែនហើយ ! នាងពិនិត្យមើលគេមួយសន្ទុះ ក៏នឹកដល់ករណីផ្ទាល់ខ្លួន :

- យើងដើរជាមួយបងណាងការពារពេលកាត់ព្រៃ, ញ៉ាំបាយជាមួយគ្នា... បើការនេះនេះតែបន្តទៅទៀតយើងសប្បាយយ៉ាងណា ?

នាងក្រមុំស្រមៃឃើញតែជីវភាពថ្មី, នាងមិនរវល់ខឹងនឹងអ្នករត់តុដែលមិនចូលមកបំរើឡើយ ។ មួយសន្ទុះក្រោយ ស្រាប់តែឮសម្លេងមួយស្រែកខ្លាំង ។ ខាងក្រៅ :

- អឺយ៉ា ! កន្លែងនេះមានស្រាមានសាច់រ៉ុយ ! យើងកំពុងតែឃ្លានស្រាប់ផង, ត្រូវប៉ាច់ហើយ ! ស៊ីផងានភ្ញាក់ក្រញាង ... បន្ទាប់មកឃើញស្រមោលមនុស្សដើរចូលមក គឺចិនមិនហួសប្អូនទាំងប្រុសតែម្ដង ! មាឌភាពក៏យ៉ាណាស់ នឹកថារឹតរើហើយផាន់ហ្គីង ។ នាយបែរមុខចេញមិនហ៊ានឲ្យគាចិនមិនហួសប្អូនឃើញ, ចិនតុងពោលតិចៗ:

- ពីពីតាខ្ញុំតើ ! បងកុំងាកមើលគាត់ណា ! ចាំខ្ញុំទៅតែងខ្លួនសិន ។

ស៊ីផងានមិនទាន់ឆ្លើយផងនាងរត់គេចទៅក្រោយផ្ទះភ្លាម ។

ចិនមិនហួសប្អូន ចូលមកដល់ មិនឃើញតុមួយណាទំនេរសោះ, រីតុតូចនៅកៀនជញ្ជាំងទទេស្អាតឥតឃើញចានក្បានអ្វីទេ ក៏ដើរទៅដាក់គូទអង្គុយលើកៅអីវែងកណ្ដាលគេ ហើយរុញស្នាមេធ្វើប្រាមនុស្សប្រញាប់ក្បែរនោះឲ្យទុកកន្លែងសំរាប់គាត់ ។ ជននោះទាំងក្រោកប្រឹងប្រឡៀតទៅវិញ ដោយនឹកថាកញ្ចាស់សក់ស្កូវនេះខ្លាំងពូកែប៉ុណ្ណាបានជាសម្បើមម្ល៉េះ ? ចាល់តែប្រានគាត់ឲ្យប៉ើងទៅវិញទើបសមឬ ?

ប៉ុន្តែគ្រាន់តែប៉ះខ្លួនគាចាស់ភ្លាម កម្លាំងមួយរត់ចេញពីប្រាណគាចាស់ទោកបក់លើគាត់ឲ្យរបអង្គុយលើកៅអីវែងដាប់ , ទ្រេតជងកាយហៀបធ្លាក់ តែចិនមិនហួសប្អូនលូកដៃចាប់ជាប់

ពោលថា៖

- មិនបាច់គួរសមពេកទេ, យើងអង្គុយកន្ទែលនេះពីរនាក់បានហើយ ។

ជននោះក្រហមមុខដោយក្ដីអៀនខ្មាស, តាចាស់សើចហេសៗ៖

- អញ្ចើញ! អញ្ចើញពិសាស្រាចុះ!

ពេលចប់តាចាស់លើកចានស្រានៅពីមុខជននោះផឹកក្អឹកៗ ព្រមទាំងលូកចង្កឹះចាប់សាច់គោមួយដុំ ទំពាផ្ងាច់ៗ យ៉ាងឆ្ងាញ់ ។

ជនដែលអង្គុយរួមតុទាំងប៉ីគ្មានមួយណាស្គាល់ចឹងមិនហួសប្អូនទេ, តែគេស្គាល់ជនអង្គុយក្បែរគាត់ជាអ្នកខ្លាំងពូកែគ្រាន់បើដែរ ម៉េចតាចាស់ប្រជ្រៀតចង់ជួលបែបនេះ ? តាចាស់ប្រហែលមិនមែនជនធម្មតាទេ ។

ចឹងមិនហួសប្អូនហូបសាច់ផឹកស្រាឆ្ងាញ់រីករាយតែម្នាក់ឯង ។ ជនឯទៀតជិតម្ភៃនាក់នោះ ដាក់ចាន ដាក់ចង្កឹះចុះ សង្កេតឫកពាតាចាស់គ្រប់ៗគ្នា ។

ចឹងមិនហួសប្អូនសួរដូចភ្ញាក់ថា៖

- ម៉េចអ្នកកាល់គ្នាមិនផឹកស្រា?

សួរចប់ គាត់កញ្ឆក់ចានស្រានៅពីមុខជនចំណាស់កងស្គមមួយរូបទៀត លើកផឹកក្អឹកៗជាងពាក់កណ្ដាល ទើបលើកដៃជូតមាត់ខ្ញាកហើយពោល៖

- ស្រានេះដូចជាជូរណាស់ទី!

តាចាស់កងស្គមខំអត់ទ្រាំទប់កំហឹងសួរវិញ៖

- លោកមាននាមដូចម្ដេចដែរ ?

ចឹងមិនហួសប្អូនសើចហាស! ហាស៖

- បើមិនស្គាល់ឈ្មោះយើងទេ, ឯងមិនមែនជាអ្នកក្លាហានខ្លាំងពូកែប៉ុន្មានឡើយ ។

តាចាស់កងស្គមជ្រួញចិញ្ចើម៖

- យើងខ្ញុំប្រកបវិជ្ជាជីវៈនៅស្រុកលាវគុងជាប់សន្ទែង មិនសូវស្គាល់នាមអស់លោកក្លាហាននៅទីនេះទេ ។ ខ្ញុំបាទឈ្មោះ ហ្វានយ៉ៃហ្វ៉ា មានងារជាកុកសនៅលាវគុង ។

ចឹងមិនហួសប្អូនញញឹមខ្លឹម៖

– សម្បុរឯងខ្មៅរលោងមានដូចតុកសពីកាលណា ? ដូចក្អែកទៅវិញទេ ។ គួរប្រែឈ្មោះថា ក្អែកខ្មៅនៅលាវតុងទើបពិរោះ ។

ហួនយើហ្វីនប្រឡោត តបវិញយ៉ាងប្រញាប់ :

–យើងមិនដែលស្គាល់គ្នាសោះ, ម៉េចឯងប្រមាថយើងដូច្នេះ ? យើងឃើញឯងចាស់ទុំទើបមិនប្រកែកប្រកាន់ ...

ជនម្នាក់ទៀតមាឌធំក្រអាញអង្គុយនៅតុមួយទៀត ពោលកាត់ :

– កញ្ចាស់នេះបែបមកពីក្រុមឈានឈ្លួទេដឹង ?

ស៊ីផានព្យាឈ្មោះ ក្រុមឈានឈ្លួបុកពោះអីបៗ, ក្រឡេកទៅម្ខាងឃើញចិនតុងតាក់តុង៏ នឹងការទ្វី ពណ៌ប្រផេះដូចអ្នកបំរើសណ្ឋាគារ នាយនៀងធ្លាប់ណាស់មិនដឹងមានក្រមុំកេទាត្យាំងមកពីណារហ័ស ម្ល៉េះ តុបតែងកាយរកមើលមិនចង់ស្គាល់ ។

ចិនតុងញញឹមពព្រាយមកអង្គុយជិតនាយខ្សឹបដាក់ត្រចៀកថា:

– អម្បាញ់មិញខ្ញុំពុំដឹងថាអ្នកបំរើម្នាក់ឯផ្ទះបាយ ហើយខ្ញុំខានអាវគេមកពាក់ដូចនេះ កុំឲ្យលោកតា ចិនមិនហួសប្អូនមើលស្គាល់ ។ បងធានទៅរៀមណា ! ខ្ញុំជួយដូតមុខឲ្យ ។

ពោលចប់ នាងលាបាតដៃចាំងពីដែលប្រឡាក់សុទ្ធតែធ្យូង លាបពេញមុខមាណពឡើងខ្មៅ ស្រមាមប៉ាត ហើយប៉ាតមុខខ្លួនឯងទៀត ។ មនុស្សម្នាក្នុងភៀវលក់បាយចាំងមូលភោជនីយដ្ឋានតែ រវល់មើលនិងស្តាប់ចិនមិនហួសប្អូនព្រោកប្រាជ្ញតក្កេងក្លាងគ្មាននរណា ងាកមើលក្រមុំកម្លោះនេះ ក្រែង ពុំមាត់ឡើយ ។

ពេលនោះចិនមិនហួសប្អូនងាកមកកេដគមាឌធំក្រអាញសើចហេៗ រួចសួរ :

– អូ, ឯងជាសិស្សក្រុមនាគខៀវឬ ? អីយ៉ា ! មានរំពាត់ ៩ កំណាត់រុំជាប់ចង្កេះហាន រាយបុកក្រអឺតក្រទមដាក់ជីតាឯងផងឬ ? ពិតជាមិនចង់រស់តទៅទៀតហើយ !

បុរសមាឌធំជានាយក្រុមនាគខៀវឈ្មោះហ៊ុងលានមែន ។ រំពាត់៩ កំណាត់នេះជាការប្រចាំត្រកូលជាច្រើនជំនាន់មកហើយ ។ ពេលនេះគាត់អព្រួចនឹកថា ចិនមិនហួសប្អូនស្គាល់ ប្រវត្តិគាត់បានសេចក្តីថាក្រុមនាគខៀវមានឈ្មោះទីងតៅដែរ ទើបគាត់ចាស់ឃើញរំពាត់ភ្លាម ស្គាល់ក្រុម បក្សគាត់ភ្លាម ។

Khmer Story Lovers



ហ្វុនលានពេញចិត្តនឹងគេស្គាល់ណាស់ ទើបឆ្លើយៈ

– មែន ! ខ្ញុំបាទឈ្មោះ ហ្វុនលានជានាយក្រុមនាគខៀវ, តើលោកតាមាននាមជាម៉េចដែរ ?

ទីងមិនហួសចួនទះគុជាំងលានខ្ទរ ហើយស្រែកខ្លាំងៗៈ

– ឈឺចិត្តណាស់, ឈឺចិត្ត ៗ...

តាចាស់ស្រែកឈឺចិត្តដល់ទៅបីដងតែគាត់លើកចានស្រាផឹកដោយទឹកមុខញញឹមញញែមហាក់គ្មានទិដ្ឋិនឹងនរណាឬឈឺចិត្តនឹងរឿងអ្វីសោះ ។ អ្នកពួកគ្នាងឿងឆ្ងល់ណាស់ ចាំស្តាប់គាត់ពោលរឿងទៀតថាៈ

– រំពាត់៩កំណាត់ប្រៀបដូចសត្វនាគពត់ពេនក្នុងលំហអាកាស . . . ឮល្បីថា នាគនៅក្នុងហ្វូងអាវុធ . . . តែពិបាកហាត់រៀនណាស់ ។ ចំណែកលំពែងឬដាវកាំបិតមិនអាចយកមកផ្ទឹមនឹងរំពាត់៩កំណាត់ឡើយ . . . ហឺ ! ឈឺចិត្តណាស់អញ ! . . . ឈឺចិត្តណាស់លោកអើយ !

ហ្វុនលានត្រេកអរជាលើកទីពីរ នឹកថាៈ

– តាចាស់នេះនិយាយពីយុទ្ធសិល្បៈប្រើរំពាត់ ៩ កំណាត់ត្រូវមួយកន្លែងៗដែរ ហាក់ដូចជាយល់ស្មៀតគុនខាងក្រុមយើងខ្លះ ។

លុះឮតាចាស់ស្រែកថាឈឺចិត្តៗ គាត់ទ្រាំមិនបាន ក៏សួរភ្លាមៈ

– តាមានរឿងអ្វីឈឺចិត្តឬ ?

ទីងមិនហួសចួនឥតវេលាឆ្លើយទេ, គាត់ងើយមើលដំបូលផ្ទះបន្តិចថាម្នាក់ឯងៈ

ពេលយើងឃើញគេប្រើកាំបិតឬដំបងយើងមិនខឹងទេ . . កាលណាគេប្រើរំពាត់៩កំណាត់យើងខឹងប្រទេះឡើងភ្លាម ! . . . អាចោរចង្រៃត្រកូលជាវនៅឈានសាប្រើរំពាត់៩កំណាត់ដែរ ។ ពីឆ្នាំទៅយើងសម្លាប់ចោលអស់ពីរនាក់ហើយ . . . នៅឈីសានមានមន្ត្រីម្នាក់ប្រើរំពាត់៩កំណាត់ទៀត ! ហ៊ឹះ ! យើងកាប់ក្បាលវាបែកខួរបាត់ស្រេច ! នៅអានហ្វៃមាននារីម្នាក់ប្រើរំពាត់៩កំណាត់ដែរ តែយើងមិនចូលចិត្តសម្លាប់ស្រីៗ ក៏គ្រាន់តែកាត់ដៃវាទាំងពីរចោលប៉ុណ្ណោះ កុំឲ្យវាកាន់អាវុធដែលមានឈ្មោះ «នាគក្នុងចំណោមអាវុធ» ទៀត !

អ្នកទាំងអស់សម្ងំស្តាប់តាចាស់និយាយយូររឹតតែភ័យឡើង មិនដឹងតាចាស់នេះមានបំណងយ៉ាង

ណាចុះពោះហ៊ុនលាន ? សំដីគាត់ពោលដាច់ៗ គ្មានក្បាលគ្មានកន្ទុយតែត្រូវទំនងរឿងពិតណាស់ ។

ត្បិតនៅស្រុកឈានសា មានបងប្អូនពីរនាក់ត្រកូលជាវប្រើរំពាត់ ៩ កំណាត់ដូចគ្នា ត្រូវគេសម្លាប់ដោយសម្ងាត់មែន ។ ឆ្នាំនេះដំណឹងលេចឮដល់ស្រុកលាវគុនយ៉ាងឆាប់រហ័ស ។

ហ៊ុនលានមានទឹកមុខស្មើ ដៃកាន់ដងរំពាត់៩កំណាត់សួរបញ្ជាក់ :

- ហេតុអីលោកស្អប់ខ្ពើមអ្នកប្រើរំពាត់៩កំណាត់ម្ល៉េះ ?

ចិនម៉ិនហួសប្អូនច្បាយសំណើចក្អាកក្អាយ:

- ម៉េចឯងថាយើងស្អប់ខ្ពើមអ្នកប្រើរំពាត់៩កំណាត់ ?

ពោលចប់គាត់លូកដៃក្នុងអាវទាញរបស់មួយចេញមកញាក់ៗ ... គឺជារំពាត់ពណ៌លឿងខ្ចីតាំងពន្លឺភ្លេក ១ មាន ៩ កំណាត់ដែរ ។ រំពាត់នេះប្រហែលធ្វើពីមាសផងក៏មិនដឹង, ដើមដងវាមានរូបក្បាលនាគ, ខាងចុងមានដាំពេជ្រ មួយគ្រាប់ភ្លឺចាំងភ្លឹក, គ្រាន់តែគ្រវីមួយភ្លាប់ផ្លេកស្មើ ព្រិបៗ ល្អមើលហើយគួរញញើតណាស់ ។ អ្នកផងទាំងឡាយភ្ញាក់ព្រើតគ្រប់គ្នានឹកថា :

- កញ្ចាស់នេះប្រើរំពាត់ ៩ កំណាត់ដែរតើ !

ចិនម៉ិនហួសប្អូនបន្តថា :

-តាប្រមក់ឯងហាត់យុទ្ធសិល្បៈបានប៉ុន្មានគាតទើបហ៊ានយករំពាត់៩កំណាត់រុំដាប់ចង្កេះទៅហើយ ? ប្រសិនបើជួបសត្រូវបានឱកាសប្រយុទ្ធគ្នាច្បាស់ជាចាញ់ច្រើនជាងឈ្នះហើយ ! បើម៉្លឹងៗមិនឲ្យអ្នកក្លាហានទាំងអស់ប្រមាថផងប្រើរំពាត់៩កំណាត់ឬ ? យើងឮថានៅស្រុកលាវគុនមានក្រុមនាគខៀវតាំងពីយូរណាស់ហើយ ជីដូនជីតាឯងប្រាំពីរប្រាំបីជំនាន់ប្រើសុទ្ធតែរំពាត់៩កំណាត់ ។ យើងចង់សម្លាប់គ្រួសារឯងអស់មួយពូជ តែស្រុកលាវគុនត្រជាក់ពេកយើងខ្ជិលទៅរកកាប់សម្លាប់គ្រួសារឯងណាស់ ... ឆ្ងាយផងត្រជាក់ផង ។ ឥឡូវបានជួបតាប្រមក់ឯងស្ពាយរំពាត់៩កំណាត់ គ្រាន់នេះស្រាប់ហើយ ! ម៉េចឯងមិនធ្វើអត្តឃាតខ្លួនទៅ,រង់ចាំដល់ណាទៀត ?

ដល់ពេលនេះទើបហ៊ុនលានយល់ថា: កញ្ចាស់នេះប្រើរំពាត់៩កំណាត់ដែរ តែមិនអនុញ្ញាតឲ្យអ្នកក្រៅប្រើការដូចគាត់ ទើបពោលពាក្យថ្លោសៗយ៉ាងនេះ ។

ហ៊ុនលានមិនទាន់ឆ្លើយយ៉ាងណាផង ស្រាប់តែសម្លេងមួយលាន់គ្រលរពីទិសខាងលិចមកថា :

- សំណាងល្អដោយកញ្ចាស់នេះមិនប្រើកាំបិត !

ទីនមិនហ្វូសប៊ូនបែរទៅរកម្ចាស់សំឡេងឃើញជនមួយរូបដុះពុកមាត់ពុកចង្កាស្រមូមក៏ស្គាល់ភ្លាម.

– បើជីតាឯងប្រើកាំបិត វាយ៉ាងម៉េចទៅវិញ ?

ជននោះឆ្លើយតប :

-យើងប្រើកាំបិតជាអាវុធយូរយារណាស់មកហើយ ។ មើលទៅឫកពាឯងដូចជាក្មេងក្លាណាស់ តែបើចង់សម្លាប់យើងពេលនេះក៏មិនដឹង ។ បើឯងសម្លាប់យើងម្នាក់បានទៅ តើឯងអាចសម្លាប់អ្នកក្លាហានទាំងអស់ដែលប្រើកាំបិតជាអាវុធបានឬទេ ?

ពោលចប់គាត់ហូតកាំបិតចេញពីស្រោមខ្វាកបោកឈឹបលើតុ ។ កាំបិតនេះមុខស្តើងខ្នង-ក្រាស់ពណ៌ស្វាយភ្លឺផ្លេកមានចងកំណាត់មួយចន្ទុះនៅជាប់នឹងដងផង ។ គ្រាន់តែគប់ឈឹបទៅ, តុរង្គើ ចានតែប៉ះទង្គិចគ្នាមួយសន្ទុះធំ បញ្ជាក់ថាកាំបិតនិងកម្លាំងដៃធ្ងន់ចំឡែកណាស់ ។

ជនពុកមាត់ស្រមូមឈ្មោះលីធីងកីងជានាយក្រុមកាំបិតញាប់ ។ ទីនមិនហ្វូសប៊ូនទម្លាក់រំពាត់ ៩កំណាត់លើតុលាន់ប្រាវ ! ហើយលូកដៃធ្វេងកញ្ឆក់កាំបិតពីជនម្នាក់ដែលអង្គុយក្បែរគាត់ស្រែកស្នូរៈ

--ទោះជាយើងប្រើកាំបិតក៏បានដែរ, ឯងចង់ម៉េច ? អីយ៉ា ! វីវរធំហើយតើ ! ឈឺចិត្តណាស់... ឈឺចិត្តណាស់អញ ! កាំបិតជាអាវុធសាមញ្ញបំផុតក្នុងពិភពគុន ក្នុងចំណោមមនុស្ស ១៩នាក់មាន១១នាក់ប្រើកាំបិតទៅហើយ !

តែក្នុងតៀមនេះមានភ្ញៀវ ១៩ នាក់អង្គុយជុំវិញតុទាំងបី ។ ក្នុងចំណោមនោះមាន ១១ នាក់ប្រើកាំបិត ។ កាលបើឃើញទីនមិនហ្វូសប៊ូនកញ្ឆក់កាំបិតពីជនម្នាក់យ៉ាងរហ័សមើលមិនទាន់, គេភ្ញាក់ផ្អើលគ្រប់គ្នាលូកដៃស្ទាបដងកាំបិតព្រមគ្នា ។ ទីនមិនហ្វូសប៊ូនស្រែកទៀត :

-យើងមានរហស្សនាមថា ទីនមិនហ្វូសប៊ូន, នៅទីនេះមានអ្នកនេះប្រើកាំបិតដល់ទៅដប់មួយនាក់, ថែមអាម្នាក់ប្រើរំពាត់៩កំណាត់ ត្រូវជាដប់ពីរ ។ អើ ! យើងចែកជាបីចំណែកទើបអាចសម្លាប់អស់ ។

ទាំងអស់គ្នាឮពាក្យ "មួយថ្ងៃមិនហ្វូសប៊ូន" មាត់ខ្លះស្រែកភ្ញាក់សម្លេងថា: នាគ ... នាគ ជាទេវរូប ។

ទីនមិនហ្វូសប៊ូនសើចហាស ! ហាស ! ពោលថា:

- ថ្ងៃនេះយើងមិនទាន់សម្លាប់ម្នាក់ណាទេ ពេលនេះត្រូវសម្លាប់ទាំងបួនជាមួយគ្នា ។

Khmer Story Lovers



តើសម្លាប់ប្អូននាក់ណាមុនគេនេះ ? ល្អើយ ! ពួកឯងចុះឈ្មោះក្នុងបញ្ជីមកចុះ , បើពុំនោះទេក្រៅពីតាក្មេងប្រើរពាក់៩កំណាត់ត្រូវឯងនាំគ្នាលុតជង្គង់សំពះយើងផប់ផងហៅយើងថា លោកតាប៉ីម៉ាត់ ទើបយើងលើកលែងជីវិតឲ្យ, មិនសម្លាប់ឯងទេ ។

ឮសម្លេងគ្រហឹមហ៊ឹះ ៗ ហើយមនុស្សប្អូននាក់ក្រោកពីតុបាយចេញទៅតំរៀបគ្នាមួយជួរ ៗ គឺហ៊ុនលាង , ហ្វានយ៉ៃហ្វ , លីធីងកិងនិងស្ត្រីម្នាក់អាយុប្រមាណសែសិបឆ្នាំ ។ ស្ត្រីនេះមិនឃើញកាន់អាវុធអ្វីទេ, លុះទៅដល់ក្រៅតៀមគាត់លើកដាយអាវបន្តិច ទើបឃើញកាំបិតខ្វាពីរដូរសស្លាបចងជាប់នឹងចង្កេះ, កាំបិតមួយៗប្រវែងជិតមួយចំអាមដោតជន្ទ្រគ្នា លើកំណាត់មួយបន្ទះម៉ាក់ប្រផ្ដាក្បៀវស្រួច ៗ ហ្វានយ៉ៃហ្វកាន់ដកមួយគូនៅដៃក្មេងស្រែកខ្លាំងៗ :

-ខ្ញុំបាទជាកុកសនៅលាវគុង ឈ្មោះហ្វានយ៉ៃហ្វ, លោកប្អូនខាងណោះឈ្មោះលាវហ៊ុនជានាយក្រុមនាគខៀវ, មួយទៀតនាមលីធីងកិងនាយក្រុមកាំបិតញាប់និងលោកស្រីកាវសានលាងជី ម្ចាស់ស្រីនៃក្រុមហ៊ុនហានមៃមានរហស្សនាមថា កាំបិតស្នៀតរហោះ ៗ យើងខ្ញុំទាំងប្អូននាក់បានដឹកនាំសិស្សគណមកកាន់ទីនេះដើម្បីបំពេញកិច្ចសន្យា, យើងនៅដំបន់លាវគុងឆ្ងាយដាច់ស្រយាល ឥតមានគំនុំអ្វីជាមួយលោកតាទីងសោះ ហេតុអីលោកតាមកប្រមាថមាក់ងាយយើងខ្ញុំដោយឥតហេតុផល ? លោកតាមានបំណងយ៉ាងណាដែរ ?

ទីងមិនហ៊ួសប្អូនសម្លឹងកាវសានលាងជីមួយសន្ទុះ ទើបពោលរៀវឆ្លាក់ឯង:

-មិនស្អាតទេ, មិនល្អមើលទេ ។

ពោលផងគាត់សម្លឹងលោកស្រីផងគ្រវីក្បាលមួយ ៗ ដូចគេឈររមើលផ្ទាំងគំនូរមិនល្អមិនត្រូវចិត្ត ៗ អ្នកឯទៀតឃើញកាយវិការតាចាស់តិះដៀលកាវសានលាងជីថាមិនស្អាត, មិនល្អគេបារម្ភគ្រប់គ្នា ព្រោះលោកស្រីចិត្តខ្លាំងដូចភ្លើងមិនដែលពួនណាពោលពាក្យអសុរសចំពោះមុខទេ ៗ

ខមួយខ្លួនគាត់ចេះយុទ្ធសិល្បៈខ្លាំងពូកែ, ខពីរដុពុកបង្កើតនិងដុពុកក្មេកសុទ្ធតែមានឈ្មោះល្បីល្បាញក្នុងដំបន់លាវគុង ៗ ជាពិសេសក្រុមហ៊ុនហានមៃសម្បូរទ្រព្យសម្បត្តិណាស់ មានតាំងពីគេហដ្ឋានធំស្កឹមស្កៃ ដីស្រែ យានជំនិះសព្វសារពើ. ទោះកាវសានលាងជីជាស្ត្រីមេម៉ាយក៏ឈ្មោះគាត់ល្បីរន្ទឺអស់មួយដំបន់លាវគុងដែរ, អ្នកគុននិយមទុច្ចរិតឬសុចរិតព្រមទាំងមន្ត្រី ប្រជារាស្ត្រនៅម្តុំនោះកោតគោរពគាត់គ្រប់គ្នា ៗ

ពេលនេះទីងម៉ិនហួសប្អូនធ្វើឲ្យគាត់អាម៉ាស់មុខក្រៃលែង ព្រោះមួយជីវិតនេះលោកស្រីមិនដែលឮនរណា ថាស់ចិត្តនឹងគាត់ រហូតពោលពាក្យមិនគប្បីចំពោះមុខឡើយ ។ កាលពីក្មេងគាត់មានសម្រស់ល្អលើសនារីទាំងពួងក្នុងដំបន់លាវគុង ហើយឥឡូវនេះទៀតនោះលោកស្រី អាយុសែសិបឆ្នាំហួយក៏មិនដែលមាននរណាបន្ទះបន្ទាប់ដូចតាទីងម៉ិនហួសប្អូនដែរ ។

នៅដំបន់លាវគុងមានទម្លាប់មួយដែលស្ត្រីគេកាន់ខ្ជាប់ខ្ជួន គឺក្បួនចរិយាសុភាពរាបសាស្លូតបូត ទោះមានអ្នកណាសរសើរពីសម្រស់ឬរូបសម្ផស្ស ក៏ស្ត្រីនោះមិនបញ្ចេញអាការៈសប្បាយពេញចិត្តដែរ ។

ពេលនេះលោកស្រីព្រួទីងម៉ិនហួសប្អូនពោលចំឡើសចំអកឲ្យបែបហ្នឹង គាត់ខឹងស្វាំងមុខ ស្រែកហៅខ្ញាំង :

– ទីងម៉ិនហួសប្អូនចេញមក ។

ទីងមិនហួសប្អូនបោះជំហានមួយៗចេញពីតៀមលក់បាយហើយសួរ:

– តើពួកឯងចាំងប្អូននេះឬ ?

ស្ទើរមិនទាន់ចប់សំនួរ គេឃើញពន្លឺផ្លេកៗផ្រេកអាកាសតម្រង់ផងខ្លួនតាហាស់ផុំផិត គឺលោកស្រីកាវសាននាងជីតបក់កាំបិតទីប្រាំដើមមកយ៉ាងរហ័សព្យាវៗ ។ ទីងមិនហួសប្អូនលាន់មាត់សរសើរ:

– រូបកង់មិនសូវស្អាតទេ, តែកាំបិត «ល្អណាស់» ។

ពោលផងលូកដៃស្តាំកន្ត្រាក់ពាត់ទិកណាត់ចេញមកត្រឡប់បញ្ចេញពន្លឺផ្លេកៗ វាយកាំបិតស្នៀតធ្លាក់អស់ប្អូន ។ កាំបិតទីប្រាំហោះតម្រង់មកទៀតទីងមិនហួសប្អូនបង់អ្នកយុទ្ធសិល្បៈផ្ទាល់ក៏មិនខ្វីគាត់រង, គាត់ហាមាត់ខាំចុងកាំបិតជាប់ភ្លាម ។ ហួនលានី, ហ្វានយីហៃ និង លីធីងកឹងស្រឡាំងកាំងមួយខណៈទើបដកកាវុធរៀងខ្លួនស៊ុះចូលព្រួ ។

ទីងមិនហួសប្អូន គេចផុតពីមុខកាំបិតលីធីងគឹងដែលវាយមកដល់មុខគេ, លើកជើងទាត់ដៃហ្វានយីហៃឲ្យដកដក់ដៃកថយក្រោយ ហើយរលាស់រំពាត់ពណ៌មាសរុំពាត់ទិកណាត់របស់ហួនលានី ។ ហួនលានីប្រឹងខ្លួនគាំងពីចេញមកម៉្លេះ, គេដឹងថាកញ្ជាស់ទីងចង់សម្លាប់គេម្នាក់គត់ ម៉្លោះហើយគេប្រឹងស្នៀតទុកជាស្រេច ។ គ្រាន់តែទីងមិនហួសប្អូនរលាស់រំពាត់មាសរុំពាត់គេភ្លាម គេរលាស់ដៃធ្វើងធ្វើឲ្យរំពាត់រឹងត្អឹត ដូចលំពែងដ៏មុតចាក់តម្រង់ទ្រូងតាហាស់ យ៉ាងរហ័សតាមស្នៀតគុនលំពែងទៅវិញ ។

Khmer Story Lovers



ព្បិតក្រុមនាគខៀវ មានយុទ្ធសិល្បៈប្រចាំត្រកូលច្រើនជំនាន់មកហើយ ។ ហុងលាងយល់ដាក់ថា ទីងម៉ិនហ្លួសប្អូនខ្លាំងពូកែណាស់ ទើបគាត់ឲ្យរំពាត់ទៅដាល់តែងគ្រវីគ្រវាត់ញ៉ូវ ៗ សំដែងស្នៀតគុនប្រចាំគ្រួសារដ៏ល្អប្រណីតតាំងពីដំបូងដៃ ។ ទីងម៉ិនហ្លួសប្អូនសរសើរខ្លាំងៗថា :

— អីយ៉េស ! ការពារចៅង្រែនេះគ្រាន់បើផង !

ពេលចប់លូកដៃស្ទាំរកចាប់ចុងរំពាត់ហុងលាង, ហុងលាងក្ដាក់ព្រើតបំប្រួញរំពាត់ឲ្យខ្លី យ៉ាងប្រញាប់ តែដៃគាចាស់ទីងម៉ិនហ្លួសប្អូនលូកតាមរហូត ., សំណាងល្អ លីធីងកិង យាតកាំបិតគាប់មកពីចំហៀងបង្ខំឲ្យទីងម៉ិនហ្លួសប្អូនដកដៃចេញ ។ ពេលនោះឮស្នូរវីវៗ យ៉ាងញាប់ គឺកាំបិតស្នៀតហោះគេចេញពីដៃលោកស្រីការ៉ សានលាងដឹមកទៀត ។ ឆាកប្រយុទ្ធចាប់ផ្ដើមជាលើកទីពីរ, ទីងម៉ិនហ្លួសប្អូនបញ្ចេញឫកពាក់ប្លែងដោយប្រយុទ្ធតទល់យ៉ាងស្ទាត់ជំនាញ ។ គាត់គ្រវីរំពាត់៩កំណាត់គ្រប់ទិសបង្កើតបានជារនាំងម្យ៉ាងភ្លឺព្រិលខ្លែកការពាររូបកាយគាត់គ្រប់ច្រក ។ គាចាស់រអ៊ូម្នាក់ឯងថា :

—ទ ! យុទ្ធសិល្បៈដំបងលាវគុងខ្ពង់ខ្ពស់ដៃរហ្ន៎ ! យើងមើលងាយពួកវាពេក ! បើចូលមកម្នាក់ម្ដងយើងមិនខ្លាចប្រើកម្លាំងកាយទេ, ពេលនេះពួកវាព្រួតគ្នាក៏ចឹងដូចជាពិបាកដែរ ។

ព្បិតជនទាំងបួនជានាយក្រុមបក្សនៅដំបងលាវគុង បានប្រមូលគ្នាធ្វើដំណើរមកសំណាក់ក្នុងភូមិហានបានមៃដើម្បីពិគ្រោះយោបល់គ្នាអំពីស្នៀតយុទ្ធសិល្បៈប្រចាំក្រុមរៀងៗខ្លួន និងរៀងបង្កើតស្នៀតគុនមួយរួមគ្នាប្រាថ្នាការពារខ្លួនគ្នាក្នុងគ្រាមានអាសន្ន ។ ផ្លូវគ្រាន់តែមកដល់ស្រុកឈាងណានក៏ប្រទះទីងម៉ិនហ្លួសប្អូនរំខានទៅហើយ, គេរួមកម្លាំងគ្នាប្រយុទ្ធតតាំងនឹងទីងម៉ិនហ្លួសប្អូនដូចបានសន្មតៗ

លីធីងកិងនិងហ្វានយីហ្វៃបូលកៀកគាចាស់, រីឯហុងលាងឈរឆ្ងាយគ្រវីរំពាត់ផងចាំមើលមានកន្លែងចន្លោះនឹងអាលវាយគ្រសុកចូលឬតែងចាំមានឱកាសគ្រវីរំពាត់រុំករុំគាចាស់ ។ រីលោកស្រីការ៉សានលាងដឹឈរឆ្ងាយសម្លក់សម្លឹងតំរង់កាំបិតស្នៀតពេលមួយៗ យ៉ាងប្រុងប្រយ័ត្នធ្វើឲ្យគាចាស់ធ្វេសម្ដង ១ ដែរ ។ ក្នុងចំណោមអ្នកទាំងបួន, ហ្វានយីហ្វៃអាចចាត់ទុកជាអ្នកខ្លាំងពូកែជាងគេ, លីធីងកិងមានកម្លាំងដៃយាតកាំបិតគាប់ម្ដងៗ លាន់សន្ធឹកខ្យល់វិចៗ . . .

ទីងគុងនិងស៊ីផងានឈរមើលឆាកប្រយុទ្ធពីក្រោយខ្នងគេដែរ ។

លីធីងកិង និងហ្វានយីហ្វៃវាយលុកព្រមគ្នា ទីងម៉ិនហ្លួសប្អូនគ្រវីរំពាត់ ខារខាំងអ្នកទាំងពីរម៉េង

ឲ្យចូលជិតគាត់ ។ ស្រាប់តែហ្វូនលានស្ទុះចូលមកគ្រវីពាត់ជិតគាត់ទៀត តាចាស់គេចភ្លែត ! ព្រះសូរវី! កាំបិតស្នៀតពីរហើរលឿនស្ទើរកាត់បំពង់កចិនមិនហ្លួសប្អូនយ៉ាងរហ័សនៅតែបន្តិចទៀតធ្លុះបំពង់កទៅហើយ តែតាចាស់ហក់គេចរហ័សដូចខ្យល់, កាំបិតកាត់ដាច់តែពុកចង្កាគាត់បួនប្រាំសរសៃ ប៉ុនតាមខ្យល់វិលវល់ ។ តាចាស់គេចផុតពីមរណៈតែអ្នកផងទាំងឡាយទះដៃហ៊ោកញ្ជ្រៀវ :

− កាំបិតស្នៀតហោះរបស់លោកស្រីកាវ សានលានដ៏អស្ចារ្យមែន !

. ចិនមិនហ្លួសប្អូនក៏យកក្តុកក្តាត់ដៃទើកថា:

− មេស្រីចង្រៃនេះគ្រាន់បើផងឬ ? បើមិនបញ្ចេញស្នៀតសម្លាប់ទេ, ថ្ងៃនេះចិនមិនហ្លួសប្អូនតាម៉ាស់មុខធំហើយ !

ក្រោយនោះគាត់ស្រែកហួចឡើង ។ ហើយគ្រវីពាត់៩កំណាត់បញ្ចេញប្រមាណក្បួនផ្លេក, ដៃម្ខាងសំរេចស្នៀតចាប់ខ្ញាំបញ្ចូលផង ។ ដៃម្ខាងគាត់ប្រើពាត់ដេញកំចាត់សត្រូវមិនឲ្យចូលជិត ដៃម្ខាងប្រើស្នៀតចាប់ខ្ញាំវាយលុកអ្នកណាដែលនៅជិតគាត់ស្រាប់ ម៉្លោះហើយហ្វូងយ៉ៅហ្វេងក៏ពុំអាចនឹងរំលងចូលជិតគាត់បាន ។ ពេលនោះអ្នកពល់គ្នាបែរជាភ័យបារម្ភជំនួសអ្នកទាំងបួនវិញ ព្រោះតាចាស់វាយសន្ធប់ឥតសំចៃកម្លាំង ។

ចំណែកស៊ីផាងគ្រាន់តែឃើញចិនមិនហ្លួសប្អូនបញ្ចេញស្នៀតចាប់ខ្ញាំ នាយអរកើតបើកភ្នែកធំៗ ទំតាមមើលដៃជើងគាត់ ។ ព្រោះស្នៀតរបស់នេះតាចិនធ្លាប់បង្រៀននាយ ហើយទូកតួចតាមជង ចម្លែឈានកាន់មួយក្រុសហើយ ។ នាយចេះចាំទាំងអស់ដោយស្រពិចស្រពិលតែមិនស្គាល់ក្បៀកក្បៀកនិងក្បាច់ច្រើនលួមប្រើការបានទេ ។

ប៉ុន្មានថ្ងៃក្រោយនេះមានពេលព្រាច់ចរជាមួយឪពុកប្តូយ ចេះសំដែងស្នៀតគុនដាវរឹតតែប្រសើរឡើងថែមទាំងបែកប្រាជ្ញាថ្មីគំនិតលើសដើមទៀត នាយតាប់ចេះនាប់យល់យុទ្ធសិល្បៈណាស់ ម៉្លោះហើយក្រឡេកឃើញចិនមិនហ្លួសប្អូនបើកជើងទាត់ធាក់ប្តូលូកដៃចាប់ក្បាពេលណា នាយយល់ដល់អត្ថន័យនិងអត្ថប្រយោជន៍របស់ស្នៀតនីមួយៗ ក្បាច់ ។ មានពេលគ្រោះអរជាអតិបរមាដោយបានដកស្រង់ការពិសោធន៍មួយប្រភេទទៀត ។

អ្នកទាំងប្រាំប្រយុទ្ធគ្នាយ៉ាងសាហាវមួយទល់នឹងបួន, ចិនមិនហ្លួសប្អូនបញ្ចេញគាយវិការនិងស្នៀតសាហាវៗណាស់ ។ មួយភ្លែតសោះគាត់លូកដៃចាប់ទាញស្លាលីជីនគិងផាប់ក្បាម, បើគឹង

គិងលើកកាំបិតកាប់ដៃចិនមិនហ្លួសប្អូនយ៉ាងប្រញាប់ ។

ស៊ីផានភ្ញាក់ព្រើតព្រោះនាយជិនឡាស់ជាកាលណាលីធីងគិងយារកាំបិតកាប់ដៃតាចាស់ឡាស់ផា ទុកតាចិនចំហាគ្រន់តែឲ្យមុខឲ្យតាចាស់កំណាចវាយឬតប់ម្នាក់ដែលកញ្ចក់កាំបិតទៀតផង ។ រីឯម្ល៉ង់ ដៃតាចិនមិនមែនអន់ខ្សោយទេ, ពិតជាអាចវាយបំបែកក្បាលលីធីងគិងធ្លាយខួរពុំខាន ។

មាណពមិនដាច់ចិត្តឲ្យតាចាស់កំណាចសម្លាប់អ្នកគុននិយមក្លាហានរូបនេះក៏របូតមាត់ស្រែកពីក្រោយៈ

-ប្រយ័ត្ន ! គាត់ចង់វាយមុខលោកហើយ !

ហេតុតែស៊ីផានមានកម្លាំងធាតុស្ទុកស្តម្ភសំដីនាយឈានខ្ពស់ លប់ស្នូរខ្យល់នៃអាវុធគ្រប់យ៉ាងធ្វើឲ្យគេឮភ្លាប់ៗគ្រប់គ្នា ។ បើធីងគិងជាអ្នកក្លាហានមួយរូបដែរ កាលឮសំដីមាណពភ្លាមគាត់ភ្ញាក់ស្មារតី ទម្លាក់កាំបិតចោល,ផ្តួលខ្លួនប្រមៀលចេញក្រៅពីរង្វង់ប្រយុទ្ធភ្លាម ។

ប៉ុន្តែចិនមិនហ្លួសប្អូនខ្លាំងក្លាណាស់, លីធីងគិងរហ័សប៉ុណ្ណឹងហើយ គង់ស្ទុះដង្ហើមដោយសារខ្យល់ដៃតាចាស់មួយសន្ទុះធំ ហើយនិងលឺផ្សាពេញមុខដូចដាច់នឹងមុខកាំបិតដូច្នោះឯង ។ លុះគេចផុតពីរបើញ្យាមទើបគាត់ស្ទុះក្រោកបោសធូលីចេញពីខោអាវទាំងភ័យខ្លួនតក់ដង្ហើមសឹងមិនដល់គ្នា ។ ព្រមពេលជាមួយនោះគាត់នឹក :

-រម្យាញមិញបើគ្មានគេជួយដាស់តឿននិងឲ្យយោបល់ល្អត្រឹមត្រូវ ម្ល៉េះយើងទៅដល់ស្ថានយមរាជបាត់ហើយ ។

លីធីងគិងផុតគ្រោះភ្លាម គេឃើញបានយ៉ៅហ្យ រង់គ្រោះថ្នាក់ដោយសារកណ្តាប់ដៃកំណាចរបស់ចិនមិនហ្លួសប្អូនម្តង ។ លីធីងគិងស្រូបខ្យល់សម្រួលដង្ហើមយ៉ាងប្រញាប់ស្រែកប្រាប់សិស្សគណៈ

- យកកាំបិតមកឲ្យយើង !

សិស្សគាត់ម្នាក់បោះកាំបិតមកភ្លាម,គាត់ចាប់ដាប់វាយសម្រុកចិនមិនហ្លួសប្អូនដើម្បីជួយគ្នីគ្នាភ្លាម ។ តែពេលនោះគេឃើញរំពាត់ពណ៌មាសរបស់តាចាស់ប្រពាត់ផាប់រំពាត់ហ្វ៊ុងលាងស្រេចទៅហើយ, ហើយចិនមិនហ្លួសប្អូនកំពុងចំរើនកម្លាំងកន្ត្រាកដងខ្លួនហ៊ុងឈានឲ្យបើងខ្លាតទៅប៉ះមុខកាំបិតលីធីងគិងវិញ ។ លីធីងគិងភ័យស្ទូនដកកាំបិតចេញហក់ថយក្រោយយ៉ាងរហ័ស ។

ខណៈនោះ ស៊ីផានស្រែកប្រាប់ទៀត :

-អីលោកគ្រូកុលហ្វានប្រយ័ត្នមែនមែន! គាត់ចាប់ខ្វាំបំពង់កលោកឥឡូវហើយ!

Khmer Story Lovers



ហ្វានយីហៀភ្ញាក់ក្រញាងឥតពិចារណាច្រើន, ក៏ត្រូវដក់ចាំងគ្នាការពារថ្ពក់ចំពាំងកក្បាល ។

ម៉ែន ! ស៊ីផានមើលកាយវិការចិនមិនហួសប្អូនយល់ចាំងអស់, ស្រាប់តែចាំងប្រាំចាប់ខ្ញាំបំពាក់កនិង មុខហ្វានយីហៀព្រឺខ្លោកៗ លេចស្នាមក្រហមច្បាស់ក្រឡៅហូរឈាមរហែម ។

ព្រឹត្តិការណ៍នេះរហ័សដូចខ្យល់ , មួយប៉ប្រិចភ្នែកសោះចិនមិនហួសប្អូនចាប់ខ្ញាំគេបានក្បាល ។

ស៊ីផានស្រែករំពឹកអ្នកក្លាហានពីររូបឲ្យគេចផុតពីក្ដីស្លាប់ បណ្ដាលឲ្យអ្នកគុននិយមមួយក្រុមនេះ ស្រែកអរជាពន្លឹក បែរមើលនាយគ្រប់គ្នា ។ គេឃើញមុខនាយប្រឡាក់ប្រឡាកប្រហែលមិនចង់ឲ្យ គេស្គាល់ ។ ចិនមិនហួសប្អូនឥតងាកមើលមីងគេទេ, គាត់ស្រែកដេរដៀលតិចៗ តែម្ដង :

- ស៊ីតារហៀង ! អាក្មេងព្រឹកណា ហ៊ានមាត់កនៅកន្លែងនេះ? បើពូកែណាស់ចេញមកប្រយុទ្ធគ្នា សាកមើល !

ស៊ីផានលៀនអណ្ដាតសួរចិនគុន :

- គាត់... គាត់ស្គាល់ខ្ញុំហើយឬ ?

ចិនគុនសម្លក់នាយដោយគ្មានក្នាញ់ឆ្លើយចំពុះមុខក្រញូវ :

- នរណាឲ្យឯងមាត់ច្រើនធ្វើអី ? ប៉ុន្តែតែឥតពូជមួយមាត់នេះមិនមែនសំដៅលើរូបឯងទេ ។

ពេលនោះលីធីងកិងនិង ហ្វានយីហៀក៏ពុងស្ទុះចូលវាយលុកយ៉ាងសាហាវ ។ ឯលោកស្រី ការសានលានជីទោលគាំបិតស្លៀកហោះជួយពីក្រៅ, ហ្វុងលានរំដោះខ្លួនរួចពីគាត់ហើយក៏ចូល ប្រឡូកយ៉ាងសកម្មទៀត ។ ចិនមិនហួសប្អូនបង់ជីងឆាប់ៗ ថាអ្នកណាមួយស្រែកប្រាប់សត្រូវ ចាំងប្អូនឲ្យគេចផុតគ្រោះភ័យ គាំងអំពេញស្លៀកស្រោចលើអ្នកចាំងប្អូនរហ័ស និងញាប់ដូចគ្រាប់ភ្លៀង ប្រាថ្នាសម្លាប់ប្អូនគាត់នេះមុននឹងពេលចំនេរដៃ ។ ស៊ីផានស្ទុះបួកតាំងពីដើមមកមិនចង់ ឲ្យនរណាស្លាប់, នរណាសម្លាប់គេឡើយ ម៉្លោះហើយនាយតែងស្រែកប្រាប់មុនជានិច្ចឲ្យគេចបែប នេះ, ដែកាត់បែបនោះហាក់ដូចសប្បាយក្នុងចិត្តណាស់ ។

ក្នុងរយៈពេលមួយសន្ទុះនេះ នាយស្រែកប្រាប់លីធីងកិងប៉ែង, រំឭកហ្វានយីហៀប្អូនដង, ជួយ ប្រាប់លៀបហ្វុងលានប៉ែង ។ ម្ដងនេះចិនមិនហួសប្អូនប្រញាប់ប្រើស្លៀកដ៏សាហាវបំផុត គ្រវាត់ រពាត់មាសឡើងលើ ហើយបង្វិលកងកាយទៅលើ លោតសន្ធ្រឹមមករកលោកស្រីការសានលានជី, តែស៊ីផានស្រែកប្រាប់ថា :

– នេះជាស្នៀតសេះដើរលើអាកាស ។

ការ៉សានលាន់ជីលោតហក់គេចទាន់ តែទីន់មិនហ្វូសប៉ូនផ្ទាត់ម្រាមដៃគ្រវាស្នាក្តាំ គាត់ស្ពឹកស្រពន់កន្ត្រើកលែងរួច ។

ការ៉សានលាន់ជីមិនអន់ឯណា, គាត់លូកដៃឆ្វេងហូតកាំបិតស្នៀតពោលវៅ តម្រង់ទីន់មិនហ្វូសប៉ូនភ្លាម ។ តាចាស់ប្រញាប់ដកខ្លួនថយឈោងចាប់រំពាត់មកក្រវីញាប់ស្អេករេងកាត់កាំបិតស្នៀតពោះឮលិប ! គឹង ១ ... រួ ! កាំបិតទាំងពីរហើរត្រឡប់ទៅរកលីធីងកិនខិនហ្វុងលានវិញ គួរឲ្យស្ញើប ។ ក្នុងពេលជាមួយនោះទីន់មិនហ្វូសប៉ូនបង្ហើរខ្លួនលើអាកាសម្តងទៀតភ្លាម ។ ការ៉សានលាន់ជីបន្ទន់ចង្កេះគេចពីចុងរំពាត់ស្រាប់តែឮសម្លេងខ្សៀវខ្វា ឈាន់មកពីជុំវិញទីលានប្រយុទ្ធ ។ លោកស្រីខ្ចាតខ្ចាងឡើងលើតឹងសក់ក្បាលរកគេចមិនរួច ។

ត្បិតទីន់មិនហ្វូសប៉ូនគ្រវីរំពាត់ថ្ពក់ផ្ទួនសក់គាត់បុនគ្រវាត់កងកាយគាត់ទាំងមូលក្នុងលំហអាកាស ។ អ្នកក្លាហានទាំងបីរូបភ័យណាស់ដោយឃើញលោកស្រីធ្លាក់ក្នុងកណ្តាប់ដៃសត្រូវ ។ គេក៏មានគ្នាស្រឡាញ់គ្នាដូចបងប្អូនរួមគ្រភ៌ដែរ, កាលបើឃើញលោកស្រីរងគ្រោះដូច្នេះគេនឹកអស់សង្ឃឹមរៀងខ្លួនខ្លាចបៀសមិនផុតពីមរណៈ ព្រោះទីន់មិនហ្វូសប៉ូនកាចសាហាវណាស់ ។

អ្នកទាំងបីលោតស្រ្គុបព្រមគ្នាទៅលើទីន់មិនហ្វូសប៉ូនឥតខ្លាចស្លាប់ទៀតទេ , តាចាស់បង្វិលខ្លួនមួយជុំស្រូបដង្ហើមណែនទ្រូង ទើបហាមាត់ព្រួសផត ! កាំបិតស្នៀតដែលគាត់ខាំទុករត់ចេញពីមាត់តម្រង់ពោះលោកស្រីការ៉សានលាន់ជី ដៃឆ្វេងគាត់ប្រើស្នៀតចាប់ខ្ញាំទះតប់សត្រូវបីនាក់ឲ្យដកថយរៀងខ្លួន ។ ការ៉សានលាន់ជីនៅក្នុងលំហអាកាសឃើញកាំបិតស្នៀតខ្លួនឯងហើរតម្រង់មកគាត់នឹកថា :

– ជនទុច្ចរិតដែលស្លាប់ក្រោមស្នាដៃយើង, អន់ណាស់ក៏មានចិតសិបឬប៉ែតសិបនាក់ដែរ ។ ពេលនេះបាបកម្មតាមយកជីវិតយើងហើយ ? យើងត្រូវស្លាប់ដោយសារកាំបិតផ្ទាល់ឬ ?

ប៉ុន្តែចៃដន្យអ្វីកាំបិតស្នៀតពីរដែលទីន់មិនហ្វូសប៉ូនបញ្ជូនទៅលីធីងកិនខិនហ្វុងលាន់នោះ ត្រូវបុរសទាំងពីរគៀសចេញហើរជ្រែកខ្យល់តម្រង់ស៊ុឺផានទៅវិញ ។ ពេលនេះច្របូកច្របល់ណាស់, មាណពស្រែកព្រមានប្រាប់មួយណាក៏មិនទាន់ដែរ, ម៉្លោះហើយនាយលូកដៃស្តាំចាប់កាំបិតស្នៀតទាំងពីរដាប់ពោសរុំចេញទៅភ្លាម ។

ឮសូរតឹង ។ កាំបិតមួយហើរទៅប៉ះកាំបិត ដែលទីនមិនហួសបួន ទើបព្រួសកំទ្រង់ពោះលោកស្រី កាំបិតមួយទៀតហើរវឹរទៅកាត់ផ្នួងសក់លោកស្រីដាច់ប៉ុត ! ការសានណាងជីរបួសក្បាលពីរពាត់មាស ធ្លាក់ដាំដួលមកដីភ្លាម គាត់ទប់កម្លាំងលោតថយក្រោយបួនប្រាំម៉ែត្រ ឈរញ័រសាច់ មុខស្លាំងដូចមនុស្សស្លាប់ ព្រោះគាត់ភិតភ័យណាស់ ។ អ្នកផងទាំងឡាយចំហមាត់ធ្មុងព្រឺក្បាលខ្លាក ។មើលព្រឹត្តិការណ៍ចម្លែកនិងសាហាវភ្លេចដកដង្ហើម ភ្ញៀវស្រែកហ៊ោសរសើរអ្នកក្លាហានដែលជួយលោកស្រីផុតពីក្តីស្លាប់ ។ សូម្បីទីនមិនហួសបួនក៏ភ្ញាក់ផ្អើលមិនតិចដែរ , គាត់នឹកថា :

— បើអន្តុយតែមានអ្នកក្លាហានស្រែកប្រាប់ពីក្រៅ ឬជួយបែបហ្នឹង, យើងប្រហារសត្រូវបួនរូបនេះមិនបានទេ ។

ទីនមិនហួសបួនដកថយពីឆាកប្រយុទ្ធចេញមកក្រៅស្រែកខ្លាំង ៗ :

— មិត្តណាមកពីណា រំខានកិច្ចការរបស់យើង ? បើចិត្តសៀងកូនម៉ែសូមចេញមកសាកល្បងជាមួយគ្នាបានពីររយឬបីរយស្នៀតមើល ! កុំលេងលបលួចឆ្មក់បែបនេះមិនសមជាអ្នកក្លាហានទេ !

តាចាស់ស្រែកសួរផង ខ្សែចក្ខុដ៏ះហិង្សាសម្លក់សម្លឹងស៊ើបឆានផង, តែគាត់មើលមិនស្គាល់ ព្រោះមុខអ្នកកម្លោះប្រឡាក់សុទ្ធតែធ្យូង ។ តាមស្តាប់នាយស្រែកប្រាប់សត្រូវទាំងបួនគាត់យល់ថាជននេះប្រាកដជាស្គាល់ស្នៀតគុនរបស់គាត់ច្រើនណាស់ ជាពិសេសគេអាចបោលកាំបិតស្នៀតជួយលោកស្រីការសានណាងជីត្រូវពេលវេលាទៀត ។ មិនត្រឹមតែប៉ុណ្ណោះគេមានកម្លាំងធាតុស្តុកស្តម្ភផង ទើបកាំបិតគេប៉ះកាំបិតគាត់ឮខ្ទាំងហើយខ្ទាតទៅឆ្ងាយបាត់ស្រមោលទំរាំជ្រុះដល់ដី ។

បើនិយាយឲ្យច្បាស់ទៅ ទីនមិនហួសបួនទទួលសារភាពក្នុងពោះថាកម្លាំងគាត់ខ្សោយជាងគេមួយកំរិត ម្ល៉ោះហើយគាត់មិនសូវក្អេងក្អាងដូចមុនទេ, ពោលវាចាម្តងនេះបែបគួរសមជាងមុនច្រើន លែងជេរគេថាចោរចង្រៃឬហៅអាប្រមក់ហើយ ។

ចំណែកមាណពវិញ, ពេលដែលជួយយកអាសាគេ នាយឥតបានគិតពិចារណាទេ លុះត្រាតែឃើញកាំបិតហើរទៅផ្តាច់ផ្នួងសក់ ជួយលោកស្រីការសានណាងជីបានដូចបំណង ទើបនាយត្រេកអរនិងភ័យលាយឡំគ្នា មិនស្មានថាយុទ្ធសិល្បៈខ្លួនល្អូតលាស់ដល់ថ្នាក់ហ្នឹង ។ លុះឃើញទីនមិនហួសបួនពោលមកកាន់នាយដោយគួរសមបែបនេះ មាណពលែងនឹកនាអ្វីទាំងអស់ ឆ្លើយទៅវិញយ៉ាងស្វាហាប់ :

- លោកតាជីបួន, ខ្ញុំ... ខ្ញុំជា «អាអន្សមធំ» ណា!

ទីងម៉ិនហួសប្អូនបើកភ្នែកក្រឡង់ស្រឡាំងកាំងមួយភ្លែត ទើបធ្លាយសំណើចក្អាកក្អាយ:

- ហាស! ហា! យើងស្មានតែនរណាផ្សេង! មិនដឹងជាអាអន្សមធំឯងណា?

តាចាស់ទឹកក្តុកចិត្ត:

- កញ្ជ្រោមក់នេះធ្លាប់បាក់វៀនមើលយើងលើទូកមួយចប់ម្ដេចបានជាកំចាយគ្រូវម៉្លេះ! មានអ្វីឲ្យសង្ស័យ?

ទីងមិនហួសប្អូនលែងភ័យបែរជាក្រេវក្រោធឡើងមុខក្រហមដោយភ្នែកកំហឹង, ស្រែកសន្ធាប់:

- អាចោរចង្រៃ, មើ៍ឯងហ៊ានមករំខានកិច្ចការរបស់យើង?

ស្រែកផងតាចាស់យាររំពាត់សំពង់ក្បាលស៊ីផងានលាន់រឺត! បាណាពង្សីលខ្លួនលោកតាទន្ទ្រានគេចផុតភ្លាម ។ ទីងមិនហួសប្អូនក៏យមួយស្នៀតមិនបានសម្រេចដូចប្រាថ្នាក៏រឹតតែក្រេវក្រោធឡើង ។ គាត់គ្រវីរំពាត់វាយលុកបែបបីស្នៀតទៀត, ស៊ីផងានគេចផុតយ៉ាងកាយ...

ទីងមិនហួសប្អូនបែកពីបាណាពង្សីទុយ៉ូវបៃផុតដឹងសោះថា «អាអន្សមធំ» មិនដូចពីដើមទេ ស៊ីផងានមិនត្រឹមតែល្អូកឈាស់ខាងកម្លាំងធាតុ, ខាយល្អកលាស់លេបកម្លាំងប្រាជ្ញា យ៉ះប៉ះពិតការច្រើន យល់ស្នៀតគុនពិជ័យយុទ្ធសិល្បៈផ្សេងៗ តាមរយៈផុតកម្លាយបែបទៀត ។ ពេលនេះស្នៀតគុនតាចាស់, ដែលខាយឃើញលើកទីពីរប្រែក្លាយជាយុទ្ធសិល្បៈធម្មតាទេ ។ ខាយលោកគេចបែបនេះមកពីខាយធ្លាប់បាក់បបខ្ទបទ្វាចតាចាស់កាលនៅទន្លេឈាងកាកវោះឯង ។

ទីងមិនហួសប្អូននឿងធ្ងល់បំផុតត្រង់គាត់មិនដែលបង្ហាញស្នៀតគុនរំពាត់ដល់អាអន្សមធំ ម្ដេចឡើយពេលនេះវាមើលយល់មើលស្គាល់ដែរ? តាចាស់រឹតតែគ្រវីរំពាត់ញាប់ឡើងៗ រហូតក្លាយដូចជាដុំពពកពណ៌លឿងក្ដីផ្ទុករុំព័ទ្ធកងកាយស៊ីផងានជុំជិត ។

(នៅមានត)

Khmer Story Lovers

ចំណាំងទុកតាមលេខ ៣៧៨ ចុះថ្ងៃទី ៨ ៦-៧០ បោះពុម្ពលើកទី ១ ចំនួន ២៥០០ ក្បាល